ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ៣១៨៨ ព.ណ..ស.ជ.ព

ថ្ងៃចន្ទ ៨ រោច ខែស្រាពណ៍ ឆ្នាំចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែ កញ្ញា ឆ្នាំ ២០១៨

# សេចក្ដីជូនដំណឹង

## ស្ដីពី

## ថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ

- យោងប្រកាសអន្តរក្រសួងលេខ១៧២ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្ដីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់ និងអន្តរជាតិ

ផ្អែកតាមតម្លៃមធ្យមប្រេងឥន្ធនៈលើទីផ្សារអន្តរជាតិ ថ្លៃលក់រាយប្រេងឥន្ធនៈពីថ្ងៃទី០១ ដល់១៥ ខែកញ្ញា ឆ្នាំ២០១៨ នឹងត្រូវលក់ ៤.២១៦រៀល/១លីត្រ សម្រាប់សាំងធម្មតា EA92 និង ៤.០៦០រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត។

ដើម្បីជួយសម្រួលដល់ជីវភាពរបស់ប្រជាជន និងដោយមានការរួមចំណែកពីក្រុមហ៊ុនចែកចាយប្រេងឥន្ធនៈនៅកម្ពុជា **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា ចំនួន៤សេនដុល្លារ/លីត្រ ។

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈសម្រាប់អនុវត្ត **ចាប់ពីថ្ងៃទី០១ ដល់១៥ ខែកញ្ញា ឆ្នាំ២០១៨** នឹងចុះមក ៤.០៥០ រៀល/លីត្រ សម្រាប់សាំងធម្មតា EA92 និង ៣.៩០០ រៀល/លីត្រ សម្រាប់ប្រេងម៉ាស៊ូត ។

ការគណនាថ្លៃលក់រាយប្រេងឥន្ធនៈមានលម្អិតដូចតារាងខាងក្រោម៖

**តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា**

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ (Gasoline 92) | ប្រេងម៉ាស៊ូត/លីត្រ (Gasoil) |
|---|---|---|---|
| ១ | Average MOPS | ០,៥២២៩ ដុល្លារ | ០,៥៦៣៤ ដុល្លារ |
| ២ | ពន្ធ៖ | ០,១៧៩១ ដុល្លារ | ០,០៦៩៦ ដុល្លារ |
| | ពន្ធគយ | ០,០៧២៦ ដុល្លារ | ០,០០០០ ដុល្លារ |
| | អាករបន្ថែម | ០,០២០០ ដុល្លារ | ០,០៤០០ ដុល្លារ |
| | អាករពិសេស | ០,០៨៦៥ ដុល្លារ | ០,០២៩៦ ដុល្លារ |
| ៣ | PREMIUM | ០,២០ ដុល្លារ | ០,២៣ ដុល្លារ |
| ៤ | អាករលើតម្លៃបន្ថែម (១០% នៃ ១+២+៣) | ០,០៩០២ ដុល្លារ | ០,០៨៦៣ ដុល្លារ |
| ៥ | ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩៩២២ ដុល្លារ | ០,៩៤៩៣ ដុល្លារ |
| ៦ | ថ្លៃលក់រាយ/លីត្រ (គិតជារៀល) | ៤.០៥២ រៀល | ៣.៨៧៧ រៀល |
| ៧ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ) | ០,៩៩ ដុល្លារ | ០,៩៥ ដុល្លារ |
| ៨ | តម្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល) | ៤.០៥០ រៀល | ៣.៩០០ រៀល |

សម្គាល់៖ អត្រាប្ដូរប្រាក់ផ្លូវការ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៨ ដែលស្មើនឹង ៤០៨៤រៀល/ដុល្លារអាមេរិក

ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

## តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ

| ថ្ងៃខែឆ្នាំ | ប្រេងសាំងធម្មតា/ធុង<br>EA 92 (USD/Barrel) | ប្រេងម៉ាស៊ូត/ធុង<br>Gasoil (USD/Barrel) |
|---|---|---|
| ១៦ សីហា ២០១៨ | ៨១,៥០ | ៨៦,១៤ |
| ១៧ សីហា ២០១៨ | ៨០,៨១ | ៨៦,៨២ |
| ២០ សីហា ២០១៨ | ៨០,៦៧ | ៨៧,០៩ |
| ២១ សីហា ២០១៨ | ៨១,៤៥ | ៨៧,២៥ |
| ២៣ សីហា ២០១៨ | ៨២,៩៣ | ៨៩,២៤ |
| ២៤ សីហា ២០១៨ | ៨៣,៦៨ | ៩០,៦៣ |
| ២៧ សីហា ២០១៨ | ៨៣,៨៧ | ៩០,៧៦ |
| ២៨ សីហា ២០១៨ | ៨៤,៤០ | ៩១,៧២ |
| ២៩ សីហា ២០១៨ | ៨៣,៦០ | ៩០,៨៩ |
| ៣០ សីហា ២០១៨ | ៨៥,៥៧ | ៩២,៤៥ |
| ៣១ សីហា ២០១៨ | ៨៦,០៦ | ៩២,៣៧ |
| មធ្យមភាគ ១១ថ្ងៃ | ៨៣,១៤០០ | ៨៩,៥៧៨២ |
| មធ្យមភាគ (ដុល្លារ/លីត្រ) | ០,៥២២៩ | ០,៥៦៣៤ |

សូមបញ្ជាក់ថា ក្រសួងពាណិជ្ជកម្មមិនមែនជាអ្នកកំណត់ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាទេ គឺក្រសួងគ្រាន់តែស្រង់តម្លៃឡើង-ចុះ នៃប្រេងតាមទីផ្សារអន្តរជាតិ មកគណនាតាមប្រកាសដូចមានក្នុងឯកសារយោងខាងលើតែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ សូមសាធារណៈជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិតាមការចាំបាច់។